00752796

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 11 / 2011
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: D26/1/3

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៣/០៧-០៩-២០០៩-អវតក/កសចស(អបជ ០៦)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១

---

**សាធារណៈ: (សំណៅកោសលុប)**

**សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី"**

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង “ដីកាសម្រេចលើការដាក់សារជាថ្មីនូវសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរទាំងបីពាក់ព័ន្ធនឹងសំណុំរឿង 00៣” ដែលបានដាក់នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២0១១ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. ប្រវត្តិនីតិវិធី និងសារណា

១. នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២00៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ ដែលពាក់ព័ន្ធនឹង [redacted] (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ”) ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើសំណុំរឿង 00៣[២]។

២. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២0១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ[៣]។

៣. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២0១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី[៤] (រួមបញ្ចូលគ្នាជា “សំណើសុំបំពេញកិច្ចស៊ើបសួរ”) ដោយបានបង្ហាញនូវឯកសារ

---

[១] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង “សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួន បីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង 00៣” ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២0១១ ឯកសារលេខ D26/1/1។

[២] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹង [redacted] ចុះថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨ ឯកសារលេខ D1។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩ ឯកសារលេខ D1/1។

[៣] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២0១១ ឯកសារលេខ D13។

[៤] សំណើបំពេញកិច្ចស៊ើបសួរលើកទី១ របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង 00៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២0១១ ឯកសារលេខ D17 ( “សំណើលើកទី១ សុំបំពេញកិច្ចស៊ើបសួរ”); សំណើលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក [redacted] ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២0១១ ឯកសារលេខ D18 (“សំណើលើកទី២ សុំបំពេញកិច្ចស៊ើបសួរ”)។ សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង [redacted] និងទី

បន្ថែមទៀតដែលត្រូវបានផ្ទេរពីសំណុំរឿង ០០២ ទៅសំណុំរឿង ០០៣ ហើយបានស្នើសុំឱ្យបញ្ចូលឯកសារមួយចំនួននៅក្នុងសំណុំរឿង ០០៣ ព្រមទាំងស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្ម ព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៤. នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ("ដីកាសម្រេចទី១ របស់សហចៅក្រមស៊ើបអង្កេត")[៥] ដោយច្រានចោលសំណើសុំបំពេញកិច្ចស៊ើបសួរ ចាត់ទុកជាមោឃៈ ដោយផ្អែកលើមូលដ្ឋានថា វិធានផ្ទៃក្នុង "ពុំទុកលទ្ធភាពឱ្យសហព្រះរាជអាជ្ញាណាម្នាក់បំពេញកិច្ចតែម្នាក់ឯងឡើយ លើកលែងតែមានការធ្វើប្រតិភូកម្មអំណាច អនុលោមតាមវិធាន ១៣(៣) នៃវិធានផ្ទៃក្នុង ឬ លើកលែងតែករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ត្រូវបានធ្វើកំណត់ហេតុ អនុលោមតាមវិធាន ៧១(១) នៃវិធានផ្ទៃក្នុង"[៦]។

៥. ក្រោយពីទទួលបានដីកាសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេតមក សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើកំណត់ហេតុជាផ្លូវការលើការខ្វែងយោបល់គ្នាជាមួយនឹងសហព្រះរាជអាជ្ញាជាតិទាក់ទិននឹងសំណើសុំបំពេញកិច្ចស៊ើបសួរ[៧]។ នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយស្នើសុំឱ្យទទួលស្គាល់សំណើនេះជាកិច្ចដែលបានបំពេញត្រឹមត្រូវ ក្រោយពីរយៈកំណត់ចំនួន ១៥ ថ្ងៃដូចបានកំណត់នៅក្នុងវិធាន

---

តាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D19 ("សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួរ")។

[៥] ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D20/3 ("ដីកាសម្រេចទី១ របស់សហចៅក្រមស៊ើបអង្កេត")។

[៦] ដីកាសម្រេចទី១ របស់សហចៅក្រមស៊ើបអង្កេត កថាខណ្ឌ ៥។

[៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

៦៦(១) នៃវិធានផ្ទៃក្នុង អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង បានផុតរលត់[៨]។ នៅក្នុងពេលជាមួយគ្នានេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេត[៩]។

៦. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចរបស់ខ្លួនស្តីអំពីការដាក់សារជាថ្មី នូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ("ដីកាដែលរងការជំទាស់")[១០] ដោយបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរដែលបានដាក់សារជាថ្មីទាំងបីនោះ។ ទីមួយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ខ្លួនមិនអាចសម្រេចលើបញ្ហានានា ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណើសុំដែលបានដាក់សារជាថ្មីនោះឡើយ ដោយសារតែអង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទី១ របស់ពួកគាត់រួចហើយ ដែលនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទាំងទឡ្ហីករណ៍ អំពីបញ្ហាទម្រង់បែបបទផង ទាំងអំពីបញ្ហាច្បាប់ផង ដូច្នេះ អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចផ្តាច់មុខក្នុងការសម្រេចអំពីសុពលភាពនៃសំណើសុំទាំងនេះដែលបានដាក់កាលពីដើមដំបូង[១១]។ ទីពីរ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត "មិនអាច" អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង តាមការស្នើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិបានឡើយ ដោយហេតុថា

---

[៨] សំណើបំពេញកិច្ចស៊ើបសួរលើកទី១ របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D22 កថាខណ្ឌ ១-៣។ សំណើលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក [redacted] ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D23។ សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង [redacted] និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D24 (រួមបញ្ចូលគ្នាជា "សំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដែលបានដាក់ឡើងវិញ")។

[៩] សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿងលេខ ០០៣" អនុលោមតាមវិធាន ៧៤(២) និងវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D20/4។ សារណាបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១។

[១០] ដីកាសម្រេចស្តីអំពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ D26 ("ដីកាដែលរងការជំទាស់")។

[១១] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៥។

៖ i) ការពន្យាររយៈពេលកំណត់ ១៥ថ្ងៃ បន្ទាប់ពីការបញ្ចប់កិច្ចស៊ើបសួរ ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៦(១) នឹងរំលោភទៅលើគោលការណ៍ជាសារវ័ន្ត ដែលមានចែងនៅក្នុងវិធាន ២១(៤) ថា ការសម្រេចសេចក្តីលើការចោទប្រកាន់ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ii) សហព្រះរាជអាជ្ញាអន្តរជាតិ ដែលអាចដាក់សំណើសុំបំពេញកិច្ចស៊ើបសួរយ៉ាងហោចណាស់ ចាប់តាំងពីថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ បែរជាបានសម្រេចរង់ចាំរហូតដល់ក្រោយពេលការបិទកិច្ចស៊ើបសួរទៅវិញ iii) សហព្រះរាជអាជ្ញាអន្តរជាតិហាក់ដូចជាធ្វើការពិចារណាមិនបានគ្រប់គ្រាន់ ទៅលើលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការជាមូលដ្ឋានដែលមានចែងនៅក្នុងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលកំណត់អំពីយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក iv) អនុលោមតាមវិធានផ្ទៃក្នុង ៥៥(១) កិច្ចស៊ើបសួរទៅលើលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការជាមូលដ្ឋានគួរតែជាអាទិភាព ហើយការបន្តកិច្ចស៊ើបសួរបន្ថែម ទៅលើបញ្ហាផ្សេងៗទៀតនឹង "បណ្តាលឱ្យមានការប្រើប្រាស់ធនធានតុលាការក្នុងលក្ខណៈដែលមិនចាំបាច់ និងមិនទទួលខុសត្រូវ"[១២]។

៧. នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលរងការជំទាស់[១៣] និងនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ គាត់បានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់គាត់។ ជាបញ្ហាបឋម សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា គាត់មានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍របស់គាត់តែម្នាក់ឯង ប៉ុន្តែដោយមានការប្រុងប្រយ័ត្នបំផុតនោះ គាត់បានធ្វើកំណត់ហេតុជាផ្លូវការមួយ អំពីការខ្វែងយោបល់គ្នា មុនពេលមានការដាក់បណ្តឹងឧទ្ធរណ៍នេះ[១៤]។ នៅផ្នែកអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គបុរេជំនុំជម្រះប្រកាសថា ដីកាដែលរងការជំទាស់គ្មានសុពលភាព និងបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតឆ្លើយតបនឹងសំណើសុំបំពេញកិច្ចស៊ើបសួរដែលបានដាក់សារជាថ្មី លើអង្គសេចក្តី។ ទីមួយ គាត់បានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមានកំហុសផ្នែកអង្គច្បាប់ និងរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលបានដាក់សារជាថ្មី ដោយឈរ

---

[១២] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៦។

[១៣] សេចក្តីជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹង "សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការដាក់សារជាថ្មីនៃសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ" ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ D26/1។

[១៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

លើមូលដ្ឋាននៃការរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយសារតែបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទី១ របស់សហចៅក្រមស៊ើបអង្កេត ដែលពុំបានដោះស្រាយទៅលើខ្លឹមសារ នៃសំណើសុំបំពេញកិច្ចស៊ើបសួរ និងនៅគ្រប់កាលៈទេសៈទាំងអស់ពុំមានអានុភាពព្យួរនោះទេ ("មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍")[១៥]។ ទីពីរ សហចៅក្រមស៊ើបអង្កេតមានកំហុសយ៉ាងជាក់ស្តែងផ្នែកអង្គហេតុ នៅក្នុងការបដិសេធសំណើសុំទាំងនេះ ដោយផ្អែកលើមូលដ្ឋាននៃភាពមិនទាន់ពេលវេលា ដោយសារតែការខកខានរបស់សហចៅក្រមស៊ើបអង្កេតមិនបានជូនដំណឹងដល់សហព្រះរាជអាជ្ញាអំពីការស៊ើបសួរដែលខ្លួនបានបើកធ្វើ រហូតដល់ជិតពេលត្រូវធ្វើសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ អនុលោមតាម វិធានផ្ទៃក្នុង ៦៦(១) ដែលមានន័យថា សហព្រះរាជអាជ្ញាអន្តរជាតិមិនមានលទ្ធភាព ក្នុងការតាមដានកិច្ចស៊ើបសួរ និងនៅក្នុងការធ្វើសេចក្តីសម្រេចមួយដែលមានបញ្ជាក់មូលហេតុ អំពីភាពចាំបាច់ ត្រូវធ្វើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាបន្ថែមទៀតនៅមុនថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ("មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ ផ្នែកទីមួយ"[១៦]។ សហចៅក្រមស៊ើបអង្កេតក៏បានរំលោភលើ ឆន្ទានុសិទ្ធិរបស់ខ្លួនផងដែរ ដោយមិនបានពន្យាររយៈពេលកំណត់ ១៥ថ្ងៃ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិបានកែតម្រូវលើកង្វះខាតផ្នែកបច្ចេកទេស ដែលត្រូវបានចោទប្រកាន់ ("មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ ផ្នែកទីពីរ")[១៧] ហើយផលប្រយោជន៍របស់ជនសង្ស័យ អ្នកដែលអាចក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ត្រូវបានខូចខាត ដោយសារការស៊ើបសួរមួយដែលជាក់ស្តែងមិនត្រូវបានបំពេញចប់សព្វគ្រប់បែបនេះ ("មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ ផ្នែកទីបី")[១៨]។ ទីបី សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយធ្វើសេចក្តីសន្និដ្ឋានមួយលើយុត្តាធិការលើរូបបុគ្គលរបស់តុលាការ ជុំវិញ"បញ្ហាយុត្តាធិការជាមូលដ្ឋាននៅក្នុងសំណុំរឿង ០០៣" ដោយមិនបានបំពេញកិច្ចស៊ើបសួរឱ្យបានពេញលេញ និង ដោយប្រុងប្រយ័ត្នទៅលើតួនាទី ឬឋានៈនៅក្នុងរចនាសម្ព័ន្ធរបស់ជនសង្ស័យ ឬអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តិដោយជនសង្ស័យទាំងនោះ ហើយសហចៅក្រមស៊ើបអង្កេតក៏មិនបានចេញដីកាសម្រេច ដែលមានសំអាងហេតុណាមួយ ពាក់ព័ន្ធនឹងយុត្តាធិការដែលជនត្រូវចោទណាម្នាក់ ឬសហព្រះរាជអាជ្ញា

---

[១៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ២៣-២៩។

[១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៣០-៣៣។

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៤-៣៥។

[១៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៦-៣៧។

00752802



អាចប្ដឹងឧទ្ធរណ៍បានដែរ។ គេអាចអះអាងត្រឹមកម្រិតណាមួយនោះបានថា សហចៅក្រមស៊ើបអង្កេតទំនងជាចេញសេចក្ដីសម្រេចលើយុត្តាធិការលើរូបបុគ្គល ដោយផ្អែកលើមូលដ្ឋាននៃការបកស្រាយមិនត្រឹមត្រូវទៅលើច្បាប់ជាធរមាន ស្ដីអំពីយុត្តាធិការលើរូបបុគ្គលនៅ អ.វ.ត.ក ("មូលដ្ឋានទីបីនៃបណ្ដឹងឧទ្ធរណ៍")[១៩]។

៨. ពុំមានការដាក់សារណាតបណាមួយទៅនឹងបណ្ដឹងឧទ្ធរណ៍នេះឡើយ។

៩. នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួន ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលប្រឆាំងនឹងសេចក្ដីសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេតដោយប្រកាសថា សេចក្ដីសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេតនេះ ត្រូវបានតម្កល់ អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង ដោយហេតុថា អង្គបុរេជំនុំជម្រះ មិនអាចរកសំឡេងគាំទ្រលើសលុបចំនួនបួនសំឡេងលើបណ្ដឹងឧទ្ធរណ៍នេះ ("សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើសេចក្ដីសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេត")[២០]។

## II. ការបញ្ចេញយោបល់ និងសេចក្ដីសន្និដ្ឋានលើបណ្ដឹងឧទ្ធរណ៍

១០. ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនចំនួនបួនសំឡេងតាមការតម្រូវ ដើម្បីឈានទៅដល់ការធ្វើសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះឡើយ។ ដោយពិចារណាថា វិធានផ្ទៃក្នុង ៧៧(១៤) ចែងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុ យោបល់សមាជិកម្នាក់ៗរបស់អង្គជំនុំជម្រះត្រូវបានភ្ជាប់ជាមួយនឹងសេចក្ដីពិចារណាទាំងនេះ។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

---

[១៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៨-៨០។

[២០] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្ដីសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ D20/4/4 ("សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើសេចក្ដីសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេត")។

១១. ដោយហេតុថា អង្គបុរេជំនុំជម្រះមិនអាចសម្រេចលើបណ្តឹងឧទ្ធរណ៍នេះបាន វិធានផ្ទៃក្នុង ៧៧ (១៣) ចែងថា ដីកាដែលរងការជំទាស់ត្រូវបានតម្កល់។

## III. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ ៖**

ប្រកាសជាឯកច្ឆន្ទថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤(បួន) រូប យ៉ាងតិច ក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្តឹងតវ៉ាទេ។

**ភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន័យ ចុំល** **Katinka LAHUIS** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ចុំល និងចៅក្រម ហួត វុទ្ធី សុំភ្ជាប់នូវមតិយោបល់របស់ខ្លួន។

ចៅក្រម Downing និងចៅក្រម Lahuis សុំភ្ជាប់នូវមតិយោបល់របស់ខ្លួន។

## មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន, ចៅក្រម ន៉ិយ ថុល និងចៅក្រម ហួត វុទ្ធី

១. វិធាន ៦៦ (១) ចែងថា ៖ "នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់ភាគី។ល។ *ភាគីទាំងអស់មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ* ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម។ រយៈពេល ១៥ ថ្ងៃនេះ ជារយៈពេលបន្ថែមសម្រាប់ភាគី ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ដែលឆ្លើយតបនឹងគោលការណ៍ជាសារវ័ន្ត ក្នុងការធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។ ព្រោះថា ក្រៅពីរយៈពេលកំណត់នេះ គឺវិធានផ្ទៃក្នុងបានផ្តល់នូវសិទ្ធិគ្រប់គ្រាន់ដល់ភាគីទាំងអស់ ដូចដែលមានបញ្ញត្តិនៅក្នុងវិធាន ៥៥ (៦) ដែលចែងថា៖ "...។ សហព្រះរាជអាជ្ញា ... មានសិទ្ធិគ្រប់ពេលវេលា ក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងពេលម៉ោងធ្វើការ និងគោរពទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ។ និង វិធាន ៥៥ (១០) ចែងថា "នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា... អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ។

២. តាមវិធាន ៥៥ (៦) និង (១០) ខាងលើនេះ យើងយល់ឃើញថា សហព្រះរាជអាជ្ញាមានរយៈពេលគ្រប់គ្រាន់ក្នុងការតាមដានពីការវិវត្តនៃសំណុំរឿង ហើយបើពិនិត្យទៅឃើញមានការខ្វះចន្លោះក្នុងការស៊ើបសួរនូវចំណុចណាមួយ ដែលសហចៅក្រមស៊ើបអង្កេតមានការខកខានមិនបានបំពេញនោះ សហព្រះរាជអាជ្ញាអាចប្រើសិទ្ធិរបស់ខ្លួន ក្នុងការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមណាមួយ ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ។

៣. ក្នុងករណី ដែលសហចៅក្រមស៊ើបអង្កេតសម្រេចទទួលសំណើទាំងបីរបស់សហព្រះរាជអាជ្ញាវិញ នាំឱ្យរំលោភលើវិធាន ២១ (៤) ដែលចែងថា៖ "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការជំនុំជម្រះ ក្នុងរយៈពេលមួយសមស្រប" ព្រោះថា នាំឱ្យមានការពន្យារពេលមួយដោយមិនសមស្រប ដែលសហព្រះរាជអាជ្ញាខ្លួនឯងមិនបានប្រើប្រាស់សិទ្ធិដែលមានក្នុងវិធាន ៥៥(៦) និង (១០) ខាងលើ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

៤. ទាក់ទិននឹងយុត្តាធិការបុគ្គល សហចៅក្រមស៊ើបអង្កេតបានលើកពីភាពមិនច្បាស់លាស់របស់សហព្រះរាជអាជ្ញា ក្នុងការពិចារណាចំពោះលក្ខខណ្ឌដែលថា ជនសង្ស័យក្នុងសំណុំរឿង ០០៣ ត្រូវជា "មេដឹកនាំជាន់ខ្ពស់" ឬជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ ដោយឡែកក្នុងសំណើសុំសារជាថ្មីថា ជនសង្ស័យត្រូវជា "មេដឹកនាំជាន់ខ្ពស់"[១] ។

៥. ការដែលសហចៅក្រមស៊ើបអង្កេត ពុំពិចារណាដល់អង្គសេចក្ដី គឺជាការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយសំអាងហេតុថា "ការបន្តការបំពេញកិច្ចស៊ើបសួរបន្ថែម នឹងមិនធ្វើឱ្យមានការផ្លាស់ប្ដូរការវិភាគរបស់យើង អំពីបញ្ហានោះទេ ប៉ុន្តែវានឹងបណ្ដាលឱ្យមានការប្រើប្រាស់ធនធានតុលាការក្នុងលក្ខណៈដែលមិនចាំបាច់ និងមិនទទួលខុសត្រូវ"[២]។

៦. ហេតុដូច្នេះ យើងយល់ឃើញថា សេចក្ដីសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេត លើការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ មានលក្ខណៈត្រឹមត្រូវដោយឈរលើមូលដ្ឋានវិធានផ្ទៃក្នុង នៃ អ.វ.ត.ក។

ភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១១

AUDIENCE PRELIMINAIRE * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី

[១] ដីកាដែលរងការជំទាស់ D26 កថាខណ្ឌ ៦ (គ)។

[២] ដីកាដែលរងការជំទាស់ D26 កថាខណ្ឌ ៦ (ឃ)។

# មតិយោបល់របស់ចៅក្រម LAHUIS និង ចៅក្រម DOWNING

១. តាំងពីដំបូងមកម្ល៉េះ យើងត្រូវសង្កត់ធ្ងន់ថា មតិយោបល់របស់យើងក្នុងបណ្តឹងឧទ្ធរណ៍នេះកើតឡើងដោយសារអង្គបុរេជំនុំជម្រះ មិនអាចចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកទីមួយ របស់សហចៅក្រមស៊ើបអង្កេតបាន ដែលនាំមានការសន្និដ្ឋានថា ដីកាសម្រេចនេះនឹងតម្កល់ទុកជាបានការ ហើយសំណើសុំបំពេញកិច្ចស៊ើបសួរត្រូវបានបដិសេធ។

## IV. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

២. យើងបានកត់សម្គាល់ថា ដោយមានការប្រយ័ត្នប្រយែង និងការចង់បញ្ជាក់នូវគោលជំហររបស់ខ្លួនសារជាថ្មីថា ការដាក់ការខ្វែងយោបល់គ្នាពុំមែនជាការចាំបាច់ទេនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការខ្វែងយោបល់មួយ មុននឹងដាក់បណ្តឹងឧទ្ធរណ៍ ដើម្បីឱ្យស្របទៅតាមលក្ខខណ្ឌដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាសម្រេចលើកទីមួយ ដែលរង់ចាំការសម្រេចជាចុងក្រោយពីអង្គបុរេជំនុំជម្រះ ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកទីមួយនេះ[១]។ ដោយហេតុថា ពុំមានការបញ្ជាក់កាលបរិច្ឆេទនៃការដាក់ការខ្វែងយោបល់នេះ គេមិនអាចដឹងច្បាស់ ថាតើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿងបច្ចុប្បន្ន ដែលត្រូវបានដាក់នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ នោះ ត្រូវបានដាក់ក្រោយរយៈពេល ៣០ ថ្ងៃគិតពីពេលដាក់ការខ្វែងយោបល់ត្រូវបានកន្លងផុតទៅហើយ ឬយ៉ាងណាទេ[២]។ ទោះបីជាយ៉ាងណាក្តី យើងយល់ថា ចំណុចនេះមិនត្រូវក្លាយជាមូលហេតុ ដែលនាំឱ្យបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាននោះទេ។ សម្រាប់មូលហេតុដែលបានលើកឡើងនៅក្នុងមតិយោបល់របស់យើង ដែលមានភ្ជាប់ជាមួយនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទៅលើដីកាសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេត[៣] និងដោយសារថា អង្គបុរេជំនុំជម្រះមិនបានចេញសេចក្តីសម្រេចដែលតម្រូវឱ្យសហព្រះរាជអាជ្ញា

---

[១] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ២។

[២] វិធាន ៧១(៣) នៃវិធានផ្ទៃក្នុង។

[៣] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទៅលើដីកាសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេត, មតិយោបល់របស់ចៅក្រម Lahuis និង ចៅក្រម Downing, កថាខណ្ឌ ១២។

ត្រូវដាក់កំណត់ហេតុនូវការខ្វែងយោបល់គ្នា មុនពេលធ្វើសកម្មភាពតែម្នាក់ឯងនោះ យើងយល់ថា ការដាក់ការខ្វែងយោបល់គ្នាដោយសហព្រះរាជអាជ្ញាអន្តរជាតិ មុននឹងដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនទៅអង្គបុរេជំនុំជម្រះ គឺត្រូវបានធ្វើឡើងយ៉ាងមានប្រសិទ្ធភាព ទោះបីជាមានការតវ៉ាក៏ដោយ ហើយយើងយល់ស្របជាមួយសហព្រះរាជអាជ្ញាអន្តរជាតិថា ការដាក់ការខ្វែងយោបល់គ្នាពុំចាំបាច់មានលក្ខណៈផ្លូវការនោះទេ។ នៅក្នុងកាលៈទេសៈទាំងនេះ យើងយល់ថា វាជាការសមស្របដែលពុំចាំបាច់ពិចារណាទៅលើការដាក់ការខ្វែងយោបល់គ្នាទេ ហើយហេតុនេះយើងយល់ថា បណ្តឹងឧទ្ធរណ៍ដែលត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងនោះគឺមានសុពលភាព។ យើងកត់សម្គាល់បន្ថែមទៀតថា នៅក្នុងកាលៈទេសៈណាក៏ដោយ រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃទទួលដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍បានកន្លងផុតទៅ ហើយក៏ពុំមានការខ្វែងយោបល់គ្នាណាមួយត្រូវបានដាក់មកអង្គបុរេជំនុំជម្រះនោះទេ ហើយអង្គបុរេជំនុំជម្រះក៏មិនបានទទួលសារណាណាមួយពីសហព្រះរាជអាជ្ញាជាតិដែរ។

៣. ដោយសារបណ្តឹងឧទ្ធរណ៍នេះស្របតាមបទប្បញ្ញត្តិនៃវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង ហើយត្រូវបានដាក់ក្នុងរយៈពេលកំណត់ ៣០ ថ្ងៃ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនោះ[៤] យើងសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

## V. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

### បទដ្ឋាននៃការពិនិត្យបណ្តឹងឧទ្ធរណ៍

៤. តាមរយៈបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំរបស់គាត់ដើម្បីដាក់សំណើចំនួនបី ដែលមិនត្រឹមត្រូវតាមពេលវេលាកំណត់ អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។ ដោយហេតុថា វិធាននេះអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតទទួលយកការដាក់សំណើ

[៤] យើងកត់សម្គាល់ថា អនុលោមតាមវិធាន ៣៩(៥) នៃវិធានផ្ទៃក្នុង ប្រសិនបើគិតទៅដល់ការដាក់កំណត់ហេតុនៃការខ្វែងយោបល់គ្នាផងនោះ រយៈពេលកំណត់ ៣០ ថ្ងៃក្នុងការដាក់បណ្តឹងឧទ្ធរណ៍នឹងត្រូវពន្យារហូតដល់មានការព្រមព្រៀងគ្នាជាឯកច្ឆន្ទ រយៈពេល ៣០ (សាមសិប) ថ្ងៃត្រូវបានបញ្ចប់ ឬ អង្គបុរេជំនុំជម្រះបានទទួល និងបានពិចារណារួចរាល់ទៅលើវិវាទនោះ ដូចក្នុងករណីនេះ។

ដែលដាក់មិនត្រឹមត្រូវតាមពេលវេលាកំណត់ "ប្រសិនបើខ្លួនយល់ឃើញថា ត្រឹមត្រូវសមហេតុផល" ជាការចាំបាច់ដែលត្រូវអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។ ហេតុនេះការពិនិត្យឡើងវិញទៅលើដីកាដែលរងការជំទាស់គឺកំណត់ត្រឹមតែការសម្រេច ថាតើសហចៅក្រមស៊ើបអង្កេតបានអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនបានសមរម្យ ឬយ៉ាងណា ដោយអនុលោមទៅតាមលក្ខណវិនិច្ឆ័យខាងក្រោម ដែលត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៃសហប្រជាជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") ដែលត្រូវបានអង្គបុរេជំនុំជម្រះយកមកអនុវត្តយ៉ាងស៊ីសង្វាក់គ្នា នៅពេលពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចពីឆន្ទានុសិទ្ធិថា៖

> "ការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបដិសេធចោល ប្រសិនបើសេចក្តីសម្រេចត្រូវបានតវ៉ានោះ៖ (១) ផ្អែកលើការបកស្រាយមិនបានត្រឹមត្រូវនៃច្បាប់ជាធរមាន (២) ផ្អែកលើសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវទាល់តែសោះទៅលើអង្គហេតុ ឬ (៣) អយុត្តិធម៌ឬមិនសមហេតុផល ដែលនាំឱ្យមានការរំលោភអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង"[៥]។

## បញ្ហាបឋម៖ យុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការទទួលស្គាល់សុពលភាពនៃការដាក់សំណើដែលដាក់មិនត្រឹមត្រូវតាមពេលកំណត់

៥. សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា ខ្លួនត្រូវបានរាំងមិនឱ្យចេញសេចក្តីសម្រេចទៅលើសុពលភាពនៃសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីដែលបានដាក់សាជាថ្មី ពីព្រោះថា ការធ្វើដូច្នេះនឹងប៉ះពាល់ដល់យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ពោលគឺនៅពេលដែលខ្លួនចេញដីកាដែលរងការជំទាស់ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ ពីសហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកទីមួយរបស់សហចៅក្រមស៊ើបអង្កេត[៦] រួចទៅហើយ។ យើងកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋាននេះមិនស៊ីសង្វាក់ជាមួយនឹងសំអាងហេតុដទៃទៀត ដែលខ្លួនបានរៀបរាប់នៅក្នុងដីកាដែល

---

[៥] *រឿងក្តី Milosevic តទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ IT-02-54-AR73.7, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្តិជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការចាត់តាំងមេធាវីការពារក្តី, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤, កថាខណ្ឌ ៩-១០ (ជើងទំព័រត្រូវបានលុបចោល) ត្រូវបានដកស្រង់*ក្នុងចំណោមនោះ*ក្នុងសំណុំរឿងលេខ 002/19-09-2007-ECCC/OCIJ (PTC 23), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ឯកសារលេខ D164/4/13, កថាខណ្ឌ ២៦។

[៦] ដីកាដែលរងការជំទាស់, កថាខណ្ឌ ៥។ តាមរយៈទឡ្ហីករណ៍ទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់ថា សំអាងហេតុនេះនាំឱ្យមានការភាន់ច្រឡំដែលស្របតាមបទដ្ឋាននៃការសើរើបណ្តឹងឧទ្ធរណ៍ឡើងវិញ។

រងការជំទាស់ ដែលខ្លួនបានសន្និដ្ឋានយ៉ាងហោចណាស់ក៏ក្នុងកម្រិតណាមួយដែរ ទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសុំដាក់សាជាថ្មីមិនត្រឹមត្រូវតាមកំណត់។ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ យើងសន្និដ្ឋានថា បញ្ហាវិវាទនេះស្ថិតទាំងស្រុងនៅក្នុងដៃរបស់សហចៅក្រមស៊ើបអង្កេតហើយ ហើយថា ពួកគាត់មានយុត្តាធិការពេញលេញក្នុងការសម្រេចទៅលើបញ្ហានានាដែលពួកគាត់បានទទួល ដូចដែលនឹងត្រូវពន្យល់នៅខាងក្រោម។

៦. ទីមួយ យើងកត់សម្គាល់ថា ជាបញ្ហាគោលការណ៍ បណ្តឹងឧទ្ធរណ៍ណាមួយដែលបានដាក់មកអង្គបុរេជំនុំជម្រះមិនប៉ះពាល់ដល់ការបន្តកិច្ចស៊ើបសួរទេ[៧]។ ជាលទ្ធផល ការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកទី១ ដូចករណីនេះជាដើម ពុំមានអានុភាពបន្ថិចបន្តួចទាល់តែសោះទៅលើលទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបន្តកិច្ចស៊ើបសួររបស់ខ្លួន រួមមានលទ្ធភាពរបស់ពួកគាត់ក្នុងការសម្រេចទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលកំពុងរង់ចាំសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ ដែលបានដាក់មកអង្គជំនុំជម្រះនេះ ដែលបានលើកឡើងនូវបញ្ហាមួយដាច់ដោយឡែក ទោះបីបញ្ហានោះពាក់ព័ន្ធនឹងករណីនេះក៏ដោយ។

៧. ទីពីរ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិមានកំហិតមកត្រឹមបញ្ហាជាក់លាក់មួយដែលថាតើ សហចៅក្រមស៊ើបអង្កេតមានកំហុសដែរ ឬយ៉ាងណា នៅក្នុងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី ដោយចាត់ទុកថាជាសំណើសុំមិនមានសុពលភាព ដោយផ្អែកលើមូលដ្ឋានដែលថា មិនមានការចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នា មុននឹងសហព្រះរាជអាជ្ញាអន្តរជាតិដាក់សំណើសុំដោយឯកឯងនោះ។ ជាលទ្ធផល បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ជាក់លាក់លើកំហុសនីតិវិធី ហើយមិនពាក់ព័ន្ធទៅនឹងការពិនិត្យឡើងវិញរបស់អង្គបុរេជំនុំជម្រះលើបញ្ហានីតិវិធីផ្សេងៗទៀត ឬលើខ្លឹមសារនៃសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបីនោះឡើយ។ នៅពេលដែលសំណើសុំទាំងនោះត្រូវបានដាក់សារជាថ្មីរួចហើយ ដើម្បីបំពេញទៅនឹងតម្រូវការដែលចែងដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសេចក្តីសម្រេចលើកទី១ របស់ខ្លួននោះ សហចៅក្រមស៊ើបអង្កេត អាចចេញសេចក្តីសម្រេចណាមួយ បានយ៉ាងមានសុពលភាព ទៅលើបញ្ហានីតិវិធីនានា ក៏ដូចជាទៅលើខ្លឹមសារនៃសំណើសុំបំពេញកិច្ចស៊ើបសួរផងដែរ។ ក្នុងករណីណាក៏

---

[៧] វិធាន ៧៧(១១) នៃវិធានផ្ទៃក្នុងចែងថា៖ "ដោយរង់ចាំលទ្ធផលនៃនីតិវិធីរបស់អង្គបុរេជំនុំជម្រះក្រោមវិធាននេះ និងលើកលែងតែអង្គបុរេជំនុំជម្រះបង្គាប់ផ្សេងពីនេះ សហចៅក្រមស៊ើបអង្កេតអាចបន្តការស៊ើបសួររបស់ខ្លួន នៅពេលណាដែលអាចធ្វើទៅបាន"។

ដោយ ក៏សេចក្តីសម្រេចបែបនេះ នឹងមិនទទួលឥទ្ធិពលពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើភាពស្របច្បាប់នៃលក្ខខណ្ឌតម្រូវ ដែលសហចៅក្រមស៊ើបអង្កេតបានកំណត់នៅក្នុងសេចក្តីសម្រេចលើកទី១ របស់ខ្លួននោះទេ។

៨. យើងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ នៅពេលដែលពួកគាត់យល់ឃើញថា ខ្លួនត្រូវបានរារាំងពីការសម្រេច ថាតើត្រូវទទួលយកសំណើដែលដាក់មិនត្រឹមត្រូវតាមពេលកំណត់ ឬយ៉ាងណានោះ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតមានយុត្តាធិការពេញលេញ ហើយដូច្នេះ មានកាតព្វកិច្ចក្នុងការសម្រេច (i) ថាតើខ្លួនគួរទទួលយកសំណើដែលដាក់មិនត្រឹមត្រូវតាមពេលកំណត់ដែរ ឬយ៉ាងណា ដោយអនុលោមតាមវិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុង ហើយប្រសិនបើសម្រេចថា ទទួលយក (ii) ថាតើគួរត្រូវអនុញ្ញាតធ្វើតាមខ្លឹមសារនៃសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលត្រូវបានដាក់សារជាថ្មីនោះដែរឬយ៉ាងណា ដោយអនុលោមតាមវិធាន ៥៥ នៃវិធានផ្ទៃក្នុង។ យ៉ាងហោចណាស់ យើងពិចារណាឃើញថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតជឿថា បណ្តឹងឧទ្ធរណ៍ដែលត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ បង្កើតឱ្យទៅជាការរារាំងដល់ខ្លួនដើម្បីសម្រេចលើបញ្ហាណាមួយនៃបញ្ហាទាំងពីរនេះ សហចៅក្រមស៊ើបអង្កេតគួរតែបានរង់ចាំរហូតទាល់តែមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ជាមុនសិន មុននឹងខ្លួនធ្វើការសម្រេចណាមួយនោះ។

**ការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធការដាក់សំណើ ដែលដាក់មិនត្រឹមត្រូវតាមពេលកំណត់**

៩. យើងកត់សម្គាល់ឃើញថា វិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុង មានភាពទូលំទូលាយដែលវិធាននេះចែងថា សហចៅក្រមស៊ើបអង្កេតអាចទទួលស្គាល់សុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើដោយមិនត្រឹមត្រូវតាមពេលកំណត់ "ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល"។ ប៉ុន្តែ ឆន្ទានុសិទ្ធិមួយនេះ មិនអាចលើកលែងសហចៅក្រមស៊ើបអង្កេតឱ្យរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវធ្វើសេចក្តីសម្រេចដោយផ្អែកលើមូលដ្ឋានសមហេតុផល និងត្រូវធានាឱ្យបាននូវការគោរពគោលការណ៍ជាសារវន្ត ដែលមានជាធរមាននៅចំពោះមុខ អ.វ.ត.ក អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតត្រូវតែ

ពិចារណាទៅបញ្ហាពាក់ព័ន្ធទាំងអស់។ គេកត់សម្គាល់ឃើញថា វិធាននៃបណ្តាតុលាការអន្តរជាតិ ឬតុលាការដែលមានលក្ខណៈជាអន្តរជាតិនានា ផ្តល់ឱ្យអង្គចៅក្រមនូវអំណាចដើម្បីលើកលែង ឬ ដើម្បីកែតម្រូវភាពមិនប្រក្រតីខាងនីតិវិធីនានា ដូចជាការទទួលយកសំណើសុំ ដែលដាក់មិនត្រឹមត្រូវតាមពេលកំណត់ នៅពេលដែលបង្ហាញឱ្យឃើញថាមាន “បុព្វហេតុល្អ”[៨] ឬ នៅពេលដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យធ្វើដូច្នោះ[៩]។ ជាទូទៅ “បុព្វហេតុល្អ” ត្រូវបានគេពិចារណាឃើញថា ជាមូលហេតុល្អ ផ្តល់ឱ្យដោយភាគីដាក់ឯកសារ ឬសំណើសុំ ដែលបានពន្យល់អំពីកិច្ចដែលត្រូវបំពេញ ដោយមិនត្រឹមត្រូវតាមពេលកំណត់របស់គាត់នោះ[១០]។ ការពិចារណាដ៏មានសារៈសំខាន់ ត្រូវតែជាការពិចារណាទៅលើផលប្រយោជន៍នៃយុត្តិធម៌ នៅក្នុងបរិបទនៃករណីជាក់លាក់ណាមួយ។ នៅពេលសម្រេច ថាតើការដាក់ឯកសារយឺត គួរត្រូវបានទទួលយកដើម្បីផលប្រយោជន៍នៃយុត្តិធម៌ដែរឬយ៉ាងណានោះ ជាទូទៅ អង្គចៅក្រមពិចារណាទៅលើសារៈសំខាន់នៃការដាក់ឯកសារនោះ សម្រាប់សិទ្ធិរបស់ភាគីដាក់ឯកសារ ឬក្នុងន័យទូលំទូលាយជាងនេះ ត្រូវពិចារណាទៅលើសារៈសំខាន់នៃព័ត៌មានដែលមាននៅក្នុងឯកសារនោះ ដើម្បីសម្រេចអំពីបញ្ហាណាមួយ ដែលមាននៅចំពោះមុខខ្លួន និងក៏ត្រូវពិចារណាផងដែរ ទៅលើព្យសនកម្មដែលអាចមានដល់ភាគីដទៃទៀត នៅក្នុងការទទួលយកការដាក់ឯកសារហួសពេលកំណត់នោះ[១១]។ ដោយហេតុថាវិធានស្តីអំពី

---

[៨] វិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) (វិសោធនកម្មលើកទី ៤៥) វិធាន ១២៧។ វិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (SCSL) (ដែលត្រូវបានកែប្រែនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១០) វិធាន ១១៦។

[៩] បទបញ្ជារបស់តុលាការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បទបញ្ជាលេខ ២៩។ សូមមើលផងដែរ សំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង Brima* សំណុំរឿងលេខ SCSL-04-16-T សេចក្តីសម្រេចលើសំណើសុំបន្ទាន់របស់មេធាវីការពារក្តី ធ្វើឡើងតាមវិធាន ៥៤ ទាក់ទងទៅនឹងការដាក់ញត្តិស្នើសុំឱ្យរួចទោស ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងលេខ II ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦ (ដែលក្នុងករណីនេះ “ដើម្បីផលប្រយោជន៍នៃយុត្តិធម៌” អង្គជំនុំជម្រះសាលាដំបូងបានទទួលយកការដាក់ញត្តិស្នើសុំឱ្យរួចទោស ដែលបានដាក់ក្រោយពេលកំណត់)។

[១០] *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង Lukic* សំណុំរឿងលេខ IT-98-32/1-AR65.1 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើញត្តិរបស់ Sreboje Lukic ដែលស្នើសុំការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៧ (ហៅកាត់ថា “សេចក្តីសម្រេច *Lukic*”) កថាខណ្ឌ ១១ ដល់ ១២។

[១១] សាលដីកាលើសំណុំរឿង *Lukic,* កថាខណ្ឌ ១២ (ត្រង់ចំណុចដែលអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានយល់ឃើញថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការទទួលស្គាល់ឯកសារបន្ថែមពីលើចម្លើយតបរបស់ភាគីអយ្យការដែលបានដាក់យឺត ស្តីពីបណ្តឹងឧទ្ធរណ៍ស្តីពីការដោះលែងបណ្តោះអាសន្ន ដូចធ្លាប់បានធ្វើកន្លងមកដើម្បីផលប្រយោជន៍យុត្តិធម៌, ក្រោមលក្ខ

នីតិវិធីនៃបទដ្ឋានអន្តរជាតិ ស្របគ្នាទៅនឹងគោលការណ៍ទូទៅ ដែលមានចែងនៅក្នុងវិធាន ២១ (១) នៃវិធានផ្ទៃក្នុង ដែលថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវធានាឱ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីនានា វិធានស្តីពីនីតិវិធីទាំងនេះ អាចផ្តល់ជាសេចក្តីណែនាំមួយ នៅពេលវាយតម្លៃលើសុពលភាពនៃការដាក់ឯកសារហួសពេលកំណត់នៅ អ.វ.ត.ក។ ពិតណាស់ អង្គបុរេជំនុំជម្រះធ្លាប់ទទួលយកការដាក់ឯកសារមួយចំនួន បើទោះជាមានភាពមិនប្រក្រតីខាងផ្នែកនីតិវិធីក៏ដោយ ដោយផ្អែកលើមូលដ្ឋានថា ការធ្វើដូច្នេះ គឺដើម្បីផលប្រយោជន៍នៃយុត្តិធម៌[១២]។

---

ខណ្ឌត្រឹមត្រូវដោយមូលហេតុថា ឯកសារបន្ថែមមានព័ត៌មានសំខាន់ៗ ដើម្បីកំណត់អំពីហានិភ័យនៃការរត់គេចខ្លួនរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ហើយមួយវិញទៀត ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានផ្តល់ឱកាសឱ្យធ្វើការឆ្លើយតបទៅនឹងឯកសារបន្ថែមនេះ), *រដ្ឋអាជ្ញា ទល់នឹង Boskoski និង Tarculovski,* លេខសំណុំរឿង IT-04-82-AR65.3, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Ljube Boskoski ស្តីពីសំណើលើកទី២ សុំដោះលែងបណ្តោះអាសន្ន, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៦, កថាខណ្ឌ ៩ (ត្រង់ចំណុចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានទទួលស្គាល់ការដាក់បណ្តឹងឧទ្ធរណ៍យឺតយ៉ាវ ដោយហេតុថា ខ្លួនចាត់ទុកថាជាផលប្រយោជន៍នៃយុត្តិធម៌ ពីព្រោះ "បណ្តឹងឧទ្ធរណ៍នេះមានសារៈសំខាន់ធំធេងសម្រាប់សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍"), សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Muvunyi,* លេខសំណុំរឿង ICTR-2000-55A-A, សេចក្តីសម្រេចលើ "សំណើរបស់ជនជាប់ចោទ Tharcisse Muvunyi ស្នើសុំកែប្រែមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់គាត់ និងសំណើសុំពន្យារពេលដាក់សារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍" និង "សំណើរបស់រដ្ឋអាជ្ញាដែលជំទាស់ទៅនឹង "មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលបានកែប្រែរបស់ជនជាប់ចោទ Tharcisse Muvunyi" អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧, កថាខណ្ឌ ៧, ជើងទំព័រ ២២ (ដែលអនុញ្ញាតឱ្យមានការកែប្រែសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ដោយមានលក្ខខណ្ឌត្រឹមត្រូវនៅពេលអង្គជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលយល់ថាការកែប្រែនេះមានភាពចាំបាច់សម្រាប់ធ្វើឱ្យបណ្តឹងឧទ្ធរណ៍ទទួលជោគជ័យ ដូចជាការនាំទៅដល់ភាពគ្មានយុត្តិធម៌ ប្រសិនបើពុំមានការកែប្រែនេះ)។

[១២] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០១) សេចក្តីសម្រេចលើពាក្យសុំបន្ទាន់របស់សហមេធាវីប្តឹងជិតចិត្តចៅក្រម ន័យ ថុល ដោយរង់ចាំបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណី នួន ជា ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារលេខ C11/29 កថាខណ្ឌ ៨ (ដែលដើម្បីផលប្រយោជន៍នៃយុត្តិធម៌ អង្គបុរេជំនុំជម្រះបានសម្រេចថាមិនពិចារណាលើបញ្ហាកំហុសបច្ចេកទេសនានាដែលអាចមាននៅក្នុងពាក្យសុំ ដែលត្រូវបានចុះហត្ថលេខាដោយមេធាវីម្នាក់ ដែលមិនទាន់បានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឡើយទេ និងដែលមិនអាចបំពេញនូវលក្ខខណ្ឌតម្រូវ សម្រាប់ដាក់ពាក្យសុំ "ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីភាគីបានដឹងអំពីមូលដ្ឋានដែលមាននៅចំពោះមុខ" នោះ)។ សូមមើលផងដែរ សេចក្តីសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញាស្នើសុំពន្យារពេល និងចំនួនទំព័រកំណត់ ដើម្បីដាក់សារណាតបរួមទៅកាន់ អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និងបណ្តឹងឧទ្ធរណ៍របស់ភាគីជាក់លាក់មួយចំនួនទៀត ប្រឆាំងនឹងដីកាសម្រេចលើសហនក្រិដ្ឋកម្មរួម ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារលេខ D97/14/9 កថាខណ្ឌ ៧ (ដែលអង្គបុរេជំនុំជម្រះបានអនុញ្ញាតបន្ថែមពេលវេលាកំណត់ និងចំនួនទំព័រកំណត់ ដើម្បីដាក់សារណាដោយផ្អែកលើមូលដ្ឋានដែលថា ការសម្រេចបែបនេះ នឹង "ផ្តល់ឱ្យអង្គជំនុំជម្រះនូវសម្ភារៈគ្រប់គ្រាន់ ដើម្បីពិចារណាឱ្យបាន

00752813



១០. យើងទទួលស្គាល់ពីលក្ខខណ្ឌជាសារវ័ន្តដែលថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវតែបញ្ចប់ក្នុងពេលវេលាមួយដែលសមរម្យ[១៣]។ ទោះជាយ៉ាងណាក្តី គេត្រូវថ្លឹងថ្លែងចំណុចនេះទៅនឹងផលប្រយោជន៍ផ្នែកយុត្តិធម៌ដែលរួមមាន ការពិចារណាទៅលើសំអាងហេតុនានាដែលពន្យល់ពីការដាក់ឯកសារយឺតយ៉ាវ រួមទាំងផលវិបាកដែលកើតចេញពីការមិនចេញសេចក្តីសម្រេចលើអង្គសេចក្តីចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរសម្រាប់សិទ្ធិរបស់ភាគីនាពេលបច្ចុប្បន្ន និងអ្នកដែលអាចក្លាយជាភាគី និងកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបើកកិច្ចស៊ើបសួរមួយ*ឱ្យបានពេញលេញ*ផងដែរ។

១១. ទីមួយ យើងពិចារណាថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសជាក់ស្តែងទៅលើអង្គហេតុនៅពេលសន្និដ្ឋានថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញពីការយកចិត្តទុកដាក់ចំពោះការងារដោយរង់ចាំរហូតដល់កិច្ចស៊ើបសួរបញ្ចប់ ទើបខ្លួនចាប់ផ្តើមដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ[១៤] ហើយសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសលើអង្គច្បាប់ផងដែរ នៅពេលខ្លួនខកខានមិនបានពិចារណាថា ការដាក់សំណើសុំសាជាថ្មី ដែលដាក់មិនត្រឹមត្រូវតាមពេលកំណត់នេះ គឺជាការចាំបាច់ ដោយសារតែដីកាសម្រេចលើកទី១ របស់សហចៅក្រមស៊ើបអង្កេត[១៥]។ តាមទស្សនៈរបស់យើង សេចក្តីសន្និដ្ឋានដែលសមហេតុសមផលមានតែមួយដែលអាចលើកឡើងក្នុងកាលៈទេសៈនានានៃរឿងក្តីនេះ គឺថា សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញពីមូលហេតុដ៏ល្អចំពោះការយឺតយ៉ាវ ក្នុងការដាក់សំណើសុំរបស់ខ្លួនសាជាថ្មី។

១២. ជាពិសេស យើងសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានសម្រេចថា "ដោយហេតុថា ការស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ បានដំណើរការ គឺយ៉ាងហោចណាស់រាប់ចាប់តាំងពីការចេញដីកាចាត់ឱ្យស៊ើបសួរជំនួសនៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាអន្តរជាតិមាន

---

សមស្របចំពោះរាល់បញ្ហាទាំងអស់ ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍" ខណៈដែលមិនមានផលវិបាកណាមួយ ដល់ជនត្រូវចោទនោះទេ)។

[១៣] ដីកាដែលការជំទាស់, កថាខណ្ឌ ៦(ក)។

[១៤] ដីកាដែលរងការជំទាស់, កថាខណ្ឌ ៦(ខ)៖ មូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍, ផ្នែកទី១។

[១៥] តាមរយៈមូលដ្ឋានទី២ នៃបណ្តឹងឧទ្ធរណ៍ ផ្នែកទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិគ្រាន់ហាក់ចង់ចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយសន្និដ្ឋានថា ការដាក់សំណើទាំងនោះមិនត្រូវបានធ្វើឡើងត្រឹមត្រូវតាមពេលកំណត់ទេ។

រយៈពេលស្ទើរតែពេញមួយឆ្នាំ ដើម្បីស្នើសុំឱ្យមានការបំពេញកិច្ចស៊ើបសួរ ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានជ្រើសរើសយកជម្រើសនេះ រហូតដល់ក្រោយពេលមានការបិទការស៊ើបសួរ"[១៦]។ ដូចដែលបានបញ្ជាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ[១៧] របាយការណ៍ទាំងឡាយដែលបានរៀបចំធ្វើឡើងដោយមន្ត្រីស៊ើបអង្កេតក្នុងការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ជាដីកាចាត់ឱ្យស៊ើបសួរជំនួសតែមួយគត់បានដាក់នៅក្នុងសំណុំរឿងនេះ ហើយភស្តុតាងភ្ជាប់ជាមួយនឹងឯកសារទាំងនេះ មិនត្រូវបានដាក់តម្កល់ទុកនៅក្នុងសំណុំរឿងនេះឡើយ ដូច្នេះហើយទើបគាត់មិនអាចទទួលឯកសារទាំងនេះរហូតដល់ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១ ទោះបីជារបាយការណ៍ទាំងនេះត្រូវបានបញ្ចប់រួចនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១១ យ៉ាងណាក៏ដោយ[១៨]។ តាមរយៈកំណត់ហេតុនៃសំណុំរឿងនេះ ត្រូវតែមានការសង្កេតឃើញថា សំណុំឯកសារដែលបានប្រមូលនៅក្នុងដំណើរការទាំងអស់នៃការស៊ើបសួរបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ចាប់តាំងពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១១ តែប៉ុណ្ណោះ ហើយសំណុំឯកសារភាគច្រើន បានដាក់តម្កល់ទុកនៅក្នុងខែមុនការបិទការស៊ើបសួរ។ ឧទាហរណ៍ឯកសារជាង ១000 ត្រូវបានផ្ទេរពីសំណុំរឿង ០០២ នៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១១ ហើយមានឯកសារផ្ទេរបន្ថែមចំនួនជាង ១៣០ ទៀត ត្រូវបានដាក់តម្កល់ចូលនៅក្នុងសំណុំរឿង នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ ទើបតែបានដាក់បញ្ចូលនៅក្នុងសំណុំរឿង នៅចន្លោះថ្ងៃទី ២៦ និងថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១[១៩] ចំណែកឯពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះទើបតែបានដាក់បញ្ចូលចូលនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ គឺ ៤៥ នាទីមុនពេលបិទការស៊ើបសួរ។ ចំពោះការពន្យារពេលដាក់ឯកសារចូលក្នុងសំណុំរឿង ០០៣ យើងបានធ្វើការច្រានចោលរួចទៅហើយនៅក្នុងមតិយោបល់របស់យើង ដូចបានភ្ជាប់ជាមួយនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Robert Hamill (មតិ

---

[១៦] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៦(ខ)។

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

[១៨] របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ D2/1។

[១៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ឯកសារ D៦ បានដាក់ចូលនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារ D៨ បានដាក់ចូលនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ និង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី ២៧ ខែ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D១២ បានដាក់ចូលនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១។

យោបល់ស្តីពីបណ្តឹងឧទ្ធរណ៍របស់ Robert Hamill)[២០]។ ការពន្យារពេលដាក់ឯកសារនេះ មិនមានសំអាងហេតុត្រឹមត្រូវ បានធ្វើឱ្យសហព្រះរាជអាជ្ញាអន្តរជាតិមិនអាចមានលទ្ធភាពទទួលបានសំណុំរឿងបច្ចុប្បន្នភាព និងត្រឹមត្រូវ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(៦) នោះទេ។ ដោយហេតុថា គ្មានព័ត៌មានណាត្រូវបានផ្តល់ជូនសហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការបំពេញកិច្ចស៊ើបសួរ ទើបគាត់មិនមានលទ្ធភាព ដើម្បីតាមដាន និងកំណត់ថាតើកិច្ចស៊ើបសួរបន្ថែម "មានប្រយោជន៍ដល់ការស៊ើបសួរ" ឬអត់ ដែលជាលក្ខខណ្ឌមានចែងនៅក្នុង វិធាន ៥៥ (១០) នៃវិធានផ្ទៃក្នុង។ បន្ទាប់ពីបានធ្វើការពិចារណាលើលំដាប់លំដោយ និងការកំណត់ចុះកាលបរិច្ឆេទនៃការដាក់ឯកសាររួចមក យើងយល់ឃើញថា ជាក់ស្តែង សហព្រះរាជអាជ្ញាអន្តរជាតិមិនបានទទួលលទ្ធភាពអនុវត្តចំណាត់ការណាមួយឡើយ មុនពេលបិទការស៊ើបសួរនេះ។ ដូច្នេះ យើងកត់សម្គាល់ឃើញថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានដឹងថា សហព្រះរាជអាជ្ញាអន្តរជាតិ "បានជ្រើសរើសមិន" ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ មុនពេលបិទការស៊ើបសួរ គឺសហចៅក្រមស៊ើបអង្កេតមានកំហុសលើអង្គហេតុយ៉ាងច្បាស់ ហើយបានធ្វេសប្រហែសដោយមិនត្រឹមត្រូវទៅលើស្ថានភាពដែលខ្លួនបានកាត់បន្ថយសិទ្ធិ និងសមត្ថភាពជាក់ស្តែងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការតាមដានកិច្ចស៊ើបសួរនេះ។

១៣. បន្ថែមទៀត យើងក៏កត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសលើអង្គច្បាប់ ដោយមិនបានពិចារណាថា ជាដំបូង សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើបំពេញកិច្ចស៊ើបសួរចំនួនបី ក្នុងរយៈពេលកំណត់ ១៥ ថ្ងៃ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៦(១) ហើយក្រោយមក ត្រូវតម្រូវឱ្យដាក់សំណើសារជាថ្មីឡើងវិញ តាមសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើបំពេញកិច្ចស៊ើបសួរនេះថា គ្មានសុពលភាព ដោយផ្អែកលើមូលដ្ឋានថាមានវិការៈនីតិវិធី។ សេចក្តីសម្រេចនេះ បានកំណត់លក្ខខណ្ឌជាលើកដំបូង ដោយតម្រូវឱ្យដាក់កំណត់ហេតុលើការខ្វែងយោបល់ណាមួយ នៅមុនពេលដែលសហព្រះរាជអាជ្ញារូបណា អនុវត្តចំណាត់ការតែឯង។ យើងយល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានអនុវត្តចំណាត់ការយ៉ាងយកចិត្តទុកដាក់ ក្នុងការដាក់សារជាថ្មីនូវសំណើបំពេញកិច្ចស៊ើបសួរ បន្ទាប់ពីបានអនុវត្តតាម

---

[២០] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Robert Hamill ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារD11/2/4/4 មតិយោបល់របស់ចៅក្រម Lahuis និង Downing (មតិយោបល់ស្តីពីបណ្តឹងឧទ្ធរណ៍របស់ Robert Hamill) កថាខណ្ឌទី ៩។

នីតិវិធីដូចមានចែងនៅក្នុងដីកាសម្រេចទី១ ទាក់ទិននឹងចំនួនថ្ងៃកំណត់ ក្រោយពីចេញដីកាសម្រេចនេះ។ គាត់បានបង្ហាញសុឆន្ទៈ ដោយអនុវត្តចំណាត់ការភ្លាមៗ អនុលោមតាមមតិយោបល់របស់សហចៅក្រមស៊ើបអង្កេត ដូច្នេះ គាត់បានផ្តល់មូលហេតុសមរម្យចំពោះការដាក់សំណើរបស់គាត់មិនត្រឹមត្រូវតាមពេលកំណត់[២១]។

១៤. ទីពីរ យើងធ្វើការពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេត បានភ័ន្តច្រឡំលើអង្គច្បាប់ និងបានបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបានយកចិត្តទុកដាក់ទៅលើសិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ព្រមទាំងបានបំពានលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុវត្តកិច្ចស៊ើបសួរឱ្យបានគ្រប់ជ្រុងជ្រោយលើអង្គហេតុដែលខ្លួនទទួលបាន នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើទាំងនោះ ដោយគ្រាន់តែផ្អែកលើមូលដ្ឋានបញ្ហាបែបបទនីតិវិធីតែប៉ុណ្ណោះ[២២]។

១៥. នៅត្រង់ផ្នែកទាក់ទិនជាពិសេសនឹងសិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ យើងកត់សម្គាល់ឃើញថា ដំបូង សហចៅក្រមស៊ើបអង្កេតបានរារាំងសហព្រះរាជអាជ្ញាអន្តរជាតិ មិនឱ្យតាមដានកិច្ចស៊ើបសួរទេ ដោយសារមានភាពយឺតយាវក្នុងការដាក់ឯកសារទាក់ទិននឹងកិច្ចស៊ើបសួរទៅក្នុងសំណុំរឿង។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបានបដិសេធសិទ្ធិគាត់ ដោយមិនអនុញ្ញាតឱ្យគាត់ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរតែម្នាក់ឯង ដោយផ្អែកលើមូលដ្ឋានបញ្ហាបែបបទនីតិវិធីថា ជាគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ដែលសហចៅក្រមស៊ើបអង្កេតបានលើកឡើងដំបូងបំផុត នៅក្នុងប្រវត្តិដំណើរការនីតិវិធីរបស់ អ.វ.ត.ក[២៣]។ ចុងក្រោយបំផុត សហចៅក្រមស៊ើបអង្កេតបានបដិសេធគាត់ មិនឱ្យមាន

---

[២១] សម្រាប់ការបកស្រាយស្រដៀងនេះ សូមមើល សំណុំរឿង រដ្ឋអាជ្ញា *ប្រឆាំងនឹង Ivica Marijacic* និង *Markica Rebic, IT-95-14-R77.1-A,* សាលក្រម អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១៤ (ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធលើទឡ្ហីករណ៍ របស់រដ្ឋអាជ្ញាដែលថា សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី ត្រូវបដិសេធពីព្រោះថា សារណានេះ បានដាក់យឺតពេល ដោយផ្អែកលើមូលដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះគឺករណីដំបូងចាប់តាំងពីសេចក្តីណែនាំស្តីពីការអនុវត្ត បានចូលជាធរមាន ហើយជាលទ្ធផល ការណ៍ដែលចាត់ទុកថា ដើមបណ្តឹងឧទ្ធរណ៍នេះមានការភ័ន្តច្រឡំ និងយល់ច្រឡំលើការកំណត់ពេលវេលា(និងនីតិវិធី) គឺជាសំអាងហេតុសមរម្យអនុញ្ញាតឱ្យមានការដាក់បណ្តឹងឧទ្ធរណ៍ យឺតពេល)។

[២២] សេចក្តីសន្និដ្ឋាននេះទាក់ទិននឹងមូលដ្ឋានទីពីរ នៃបណ្តឹងឧទ្ធរណ៍ ផ្នែកទីបី និងមូលដ្ឋានទីបី នៃបណ្តឹងឧទ្ធរណ៍។

[២៣] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងសេចក្តីសម្រេចទី ១ របស់សហចៅក្រមស៊ើបអង្កេត មតិយោបល់របស់ចៅក្រម Lahuis និង Downing កថាខណ្ឌ ៩-១១។

ឱកាសដាក់សំណើសុំបំពេញកិច្ចស៊ើបសួរមិនត្រឹមត្រូវតាមពេលកំណត់ បន្ទាប់ពីមានការកែតម្រូវកង្វះខាតបែបបទនីតិវិធីរួចហើយ។ យើងពិចារណាឃើញថា ជារួម នីតិវិធី និងសេចក្តីសម្រេចទាំងនេះ មានអានុភាពក្នុងការរារាំងសហព្រះរាជអាជ្ញាអន្តរជាតិ មិនឱ្យអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការធ្វើសេចក្តីសម្រេចត្រឹមត្រូវលើសំណើរបស់គាត់ស្នើសុំបំពេញកិច្ចស៊ើបសួរ ហើយបើនិយាយឱ្យទូលំទូលាយជាងនេះ នេះគឺជាទង្វើរារាំងសិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ មិនឱ្យតាមដានកិច្ចស៊ើបសួរ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(១០) និង ៦៦(១)។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលដែលខ្លួនបដិសេធមិនព្រមទទួលយកការដាក់សំណើសារជាថ្មីឡើងវិញ មិនទាន់ពេលកំណត់ ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដោយអនុវត្តតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

១៦. បន្ថែមពីលើនេះ យើងក៏ពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមវិធាន ៥៥(១) នៃវិធានផ្ទៃក្នុង ក្នុងការបំពេញកិច្ចស៊ើបសួរឱ្យបានគ្រប់ជ្រុងជ្រោយ ដោយសារយ៉ាងហោចណាស់ក៏សហចៅក្រមស៊ើបអង្កេត បានបដិសេធមិនព្រមពិចារណាលើអង្គសេចក្តី នៃសំណើបំពេញកិច្ចស៊ើបសួរ[២៤] ហើយក៏មិនបានវាយតម្លៃ ថាតើកិច្ចស៊ើបសួរតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នឹងជួយបញ្ជាក់ការពិត ឬមានប្រយោជន៍សម្រាប់កិច្ចស៊ើបសួរ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(៥) និង (១០)។ យើងក៏សូមបញ្ជាក់បន្ថែមទៀតថា ការខកខានមិនបានបំពេញកិច្ចស៊ើបសួរឱ្យបានគ្រប់ជ្រុងជ្រោយ និងឥតលម្អៀង ប្រាកដជាប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យ សិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិរបស់សហព្រះរាជអាជ្ញា ជាពិសេសនៅក្នុងបរិបទដែលពួកគាត់ មិនទាន់ទទួលបានលទ្ធភាពចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងកិច្ចស៊ើបសួរនេះ[២៥]។

---

[២៤] យើងកត់សម្គាល់ឃើញថា ទោះបីជាបានធ្វើការពិចារណាដូចបានចម្លងឡើងវិញនៅក្នុងកថា ១៧ នៃមតិយោបល់នេះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត បានបដិសេធមិនទទួលយកការដាក់សំណើ អនុវត្តតាមវិធានផ្ទៃក្នុង ៣៩(៤)ដែរ ហើយយើងក៏កត់សម្គាល់ឃើញថា គ្មានសញ្ញាណអ្វីដែលបង្ហាញថា សហចៅក្រមស៊ើបអង្កេត បានពិចារណាលើអង្គសេចក្តីនៃការដាក់សារជាថ្មីនូវសំណើបំពេញកិច្ចស៊ើបសួរចំនួនបី ។

[២៥] សម្រាប់ការពិភាក្សាអំពីលទ្ធភាពដែលជនសង្ស័យ និងជនរងគ្រោះ មិនអាចចូលរួមក្នុងការស៊ើបសួរក្នុងសំណុំរឿង០០៣ សូមមើល៖ មតិយោបល់ស្តីពីបណ្តឹងឧទ្ធរណ៍របស់ Robert Hamill កថាខណ្ឌ ៥។

00752818



១៧. ដូច្នេះ យើងកត់សម្គាល់ឃើញថា នៅក្នុងដីកាដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតបានធ្វើការពិចារណាថា សហព្រះរាជអាជ្ញា "មិនអាចមើលរំលងបញ្ញត្តិនៃវិធាន ៥៥(១) ដែលបើកឱ្យមានការស៊ើបសួរចំពោះឧក្រិដ្ឋកម្ម 'ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ' តែប៉ុណ្ណោះ។ ការណ៍នេះមានន័យថា ការស៊ើបសួរដែលទាក់ទងនឹងយុត្តាធិការជាមូលដ្ឋាន ដែលមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺជាកិច្ចការអាទិភាព[២៦]" បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានថា "ការបន្តការបំពេញកិច្ចស៊ើបសួរបន្ថែមនឹងមិនធ្វើឱ្យមានការផ្លាស់ប្តូរការវិភាគរបស់យើងអំពីបញ្ហានោះទេ ប៉ុន្តែវានឹងបណ្តាលឱ្យមានការប្រើប្រាស់ធនធានតុលាការ ក្នុងលក្ខណៈដែលមិនចាំបាច់ និងមិនទទួលខុសត្រូវ"[២៧]។

១៨. ផ្ទុយពីអ្វីដែលទំនងជាជំហររបស់សហចៅក្រមស៊ើបអង្កេត វិធានជាធរមានពុំកំហិតសិទ្ធិអំណាចរបស់ ក.ស.ច.ស ក្នុងការបើកកិច្ចស៊ើបសួរឡើយ ល្គឹកណាកិច្ចស៊ើបសួរទាំងនោះ ស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ប៉ុន្តែយ៉ាងណាមិញ វិធានផ្ទៃក្នុងបានដាក់កាតព្វកិច្ចឱ្យ ក.ស.ច.ស បើកកិច្ចស៊ើបសួរអំពី "*បទល្មើស* ក្រោមដែនយុត្តាធិការ អ.វ.ត.ក"[២៨] ដែលមានន័យថា កិច្ចស៊ើបសួរ គឺធ្វើឡើងទៅលើអំពើល្មើស ដូចមានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[២៩]។ ការសម្រេចអំពីយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក ដើម្បីចោទប្រកាន់ជនណាម្នាក់ដែលបានកំណត់អត្តសញ្ញាណក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងនាមជាចារី ឬជនសមគំនិត មិនអាចនឹងធ្វើទៅបាននោះទេ ប្រសិនបើពុំមានកិច្ចស៊ើបសួរឱ្យបានពេញលេញទៅលើអង្គហេតុ ដែលជាការចាំបាច់ ដើម្បីសម្រេចថាតើ ជននោះជា "មេដឹកនាំជាន់ខ្ពស់" និង/ឬ "អ្នកទទួលខុសត្រូវខ្ពស់

---

[២៦] ដីកាដែលរងការជំទាស់ កថាខណ្ឌ៦(ឃ)។

[២៧] ដីកាដែលរងការជំទាស់ កថាខណ្ឌ៦(ឃ)។

[២៨] វិធាន ៥៥(១) នៃវិធានផ្ទៃក្នុង។ យើងសម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានដកស្រង់វិធាននេះខុសត្រង់កថាខណ្ឌ៦ (ឃ) នៃដីកាដែលរងការជំទាស់ដោយបានលុបចោលពាក្យ "បទល្មើស" ដែលជាពាក្យមានសារៈសំខាន់។

[២៩] សូមមើលវិធាន ៥៥(១) និង វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។ ពិតណាស់ អាចពុំមានជនសង្ស័យណាម្នាក់ដែលសហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណ (វិធាន៥៣(១)នៃវិធានផ្ទៃក្នុង)។ ទោះក្នុងកាលៈទេសៈណាក្តី សហចៅក្រមស៊ើបអង្កេតមានភារកិច្ចកំណត់អត្តសញ្ញាណចារីដែលទទួលខុសត្រូវចំពោះអំពើល្មើសដែលត្រូវបានចោទប្រកាន់ (វិធាន៥៥(៤), វិធាន ៦៧(៣)(ខ) នៃវិធានផ្ទៃក្នុង)។

បំផុត" ដែរឬយ៉ាងណា ក្រោមមាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[៣០] និងបន្ទាប់ពីទុកឱកាសឱ្យភាគីធ្វើសេចក្តីសន្និដ្ឋានលើបញ្ហានេះ[៣១]។ យើងកត់សម្គាល់ថា បញ្ហាផ្លូវច្បាប់ពាក់ព័ន្ធនឹងអ្នកដែលត្រូវចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ ដោយអនុលោមតាមមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កំពុងរង់ចាំការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក បន្ទាប់ពីមានការដាក់បណ្តឹងសាទុក្ខរបស់កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវបានប្រកាសនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០[៣២]។ សេចក្តីសម្រេចដែលនឹងត្រូវចេញនៅពេលខាងមុខដោយអង្គជំនុំជម្រះតុលាការកំពូល អាចនឹងមានសារប្រយោជន៍សម្រាប់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តបទប្បញ្ញត្តិខាងលើ និងក្នុងការសម្រេចលើបញ្ហា ដែលខ្លួនគិតថាមានហានិភ័យខ្ពស់។ ទន្ទឹមនឹងនោះដែរ និងដោយហេតុតែសហចៅក្រមស៊ើបអង្កេតពុំបានផ្តល់សញ្ញាណណាមួយដើម្បីធ្វើជាលក្ខណវិនិច្ឆ័យ ដែលខ្លួននឹងត្រូវពិចារណានៅពេលសម្រេចលើយុត្តាធិការបុគ្គលរបស់តុលាការចំពោះជនសង្ស័យ យើងកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិស្នើថា ការសម្រេចដូច្នេះតម្រូវឱ្យមានការស៊ើបអង្កេតអំពីតួនាទី តាមឋានានុក្រម ឬឋានៈរបស់ជនសង្ស័យ *ក្នុងចំណោមអង្គហេតុផ្សេងៗ* ដែលត្រូវស៊ើប រួមទាំងកម្រិតនៃសិទ្ធិអំណាច និងភាពអសោចន៍ ឬភាពធ្ងន់ធ្ងរនៃបទល្មើសដែលពួកគេបានប្រព្រឹត្តតាមការចោទប្រកាន់[៣៣]។ ដូចយើងបានរៀបរាប់ក្នុង

---

[៣០] ក្នុងប្រព័ន្ធច្បាប់បារាំង ដែលផ្តល់នូវការណែនាំនៅក្នុងសំណុំរឿងបច្ចុប្បន្ន ការសម្រេចប្រកាសអំពីការគ្មានសមត្ថកិច្ចរបស់តុលាការត្រង់ចំណុចដែលសហចៅក្រមស៊ើបអង្កេតពុំបានបំពេញកិច្ចស៊ើបសួរចាំបាច់ ត្រូវបានចាត់ទុកថា មានតម្លៃស្មើនឹងការបដិសេធមិនបើកកិច្ចស៊ើបសួរ (*refus d'informer*): Christian Guéry, *Instruction préparatoire*, Rép. pén. Dalloz, កថាខណ្ឌ ១៤៧; Pierre Chambon និង Christian Guéry, *Droit et pratique de l'instruction préparatoire*, Dalloz Action, ឆ្នាំ ២០០៧-២០០៨, កថាខណ្ឌ ២១.១៤ ; Crim. Cass. ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩១, Bull. Crim. លេខ ៣០០; Crim. Cass. ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧, Bull. Crim. លេខ ៧៧; Crim. Cass. ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៥, Bull. Crim. លេខ ៤២។

[៣១] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងដែលចែងថា៖ "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ"។ សម្រាប់ការពិភាក្សាស្តីពីសិទ្ធិក្នុងកិច្ចដំណើរការនីតិវិធីតទល់ សូមមើលផ្នែកស្តីពីយោបល់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ Robert Hamill, កថាខណ្ឌ ១០។

[៣២] សំណុំរឿង០០១/១៨-០៧-២០០៧-អវតក/អជតក, សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ទទ្បីករណ៍ទីមួយ។

[៣៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤១។

ផ្នែកស្តីពីយោបល់របស់យើង ដែលយើងបានដាក់ភ្ជាប់មកជាមួយនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ស្តីពីសេចក្តីសម្រេចទី១ របស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា សំណើសុំបំពេញកិច្ចស៊ើបសួរទាំងនេះមានព័ត៌មានសំខាន់ៗជាច្រើន *ដែលក្នុងចំណោមព័ត៌មានទាំងនោះ* មានព័ត៌មានទាក់ទិននឹងការជាប់ពាក់ព័ន្ធរបស់ជនសង្ស័យ ដែលមានបង្ហាញឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅក្នុងបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងដីកានោះ។ ហេតុដូច្នេះ ព័ត៌មាននេះអាចជាព័ត៌មានពាក់ព័ន្ធ និងជាព័ត៌មានចាំបាច់សម្រាប់ឱ្យចៅក្រមស៊ើបអង្កេតសម្រេច ថាតើជនសង្ស័យទាំងអស់នេះស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា។

១៩. ដោយពិចារណាទៅលើផលប្រយោជន៍នៃយុត្តិធម៌ ដែលសហចៅក្រមស៊ើបអង្កេតគួរតែបានពិចារណាដែរនោះ យើងយល់ថា ការបើកកិច្ចស៊ើបសួរឱ្យបានពេញលេញទៅលើបទល្មើសធ្ងន់ធ្ងរដូចមានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងការធានាបាននូវការគោរពសិទ្ធិរបស់ភាគី និងជនរងគ្រោះ ពិតជាមានភាពចាំបាច់ខ្លាំងជាង បញ្ហាផ្សេងៗដែលអាចនាំឱ្យមានការពន្យារពេលបន្តិចបន្តួច នៅក្នុងកិច្ចដំណើរការនីតិវិធី ជាពិសេសនៅពេលដែលជនសង្ស័យពុំទាន់បានទទួលការជូនដំណឹងជាផ្លូវការអំពីការចោទប្រកាន់ និងពុំទាន់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅឡើយ។

២០. ដោយសារសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ និងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដីកាដែលរងការជំទាស់គួរត្រូវបានបដិសេធ និងដោយសំអាងលើហេតុផលខាងលើសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី ដែលបានដាក់សាជាថ្មីពុំត្រឹមត្រូវតាមពេលកំណត់ គួរត្រូវបានទទួលស្គាល់ថា មានសុពលភាព ដោយអនុលោមតាមវិធាន ៣៩(៤)នៃវិធានផ្ទៃក្នុង។ អាស្រ័យហេតុនេះ យើងសូមបញ្ជូនបញ្ហានេះត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីសម្រេចលើខ្លឹមសារនៃសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី ដែលបានដាក់សាជាថ្មី។ ថ្វីបើដីកាដែលរងការជំទាស់ត្រូវបានតម្កល់ ដោយសារអង្គបុរេជំនុំជម្រះពុំអាចសម្រេចលើបណ្តឹងឧទ្ធរណ៍នេះបានក៏ដោយក៏យើងកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតនៅតែមានលទ្ធភាពប្រើប្រាស់ឆន្ទានុសិទ្ធិ

របស់ខ្លួន ក្នុងការពិចារណាឡើងវិញទៅលើដីកាខាងលើ[៣៤] ដោយទទួលស្គាល់នូវការពិចារណារបស់យើងស្ដីពីបទដ្ឋានអន្តរជាតិ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ចៅក្រម Rowan DOWNING

ចៅក្រម Katinka LAHUIS

[៣៤] នាពេលកន្លងមក អង្គបុរេជំនុំជម្រះបានយល់ឃើញថា ស្ថាប័នតុលាការអាចពិចារណាឡើងវិញលើសេចក្ដីសម្រេចណាមួយ ហើយខ្លួនធ្លាប់បានពិចារណាឡើងវិញលើសេចក្ដីសម្រេចនានា តាមការស្នើសុំរបស់ភាគី ឬ*តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន* បន្ទាប់ពីបានទុកឱកាសឱ្យភាគីបានដឹង។ សូមមើល *ក្នុងចំណោមចំណុចផ្សេងៗ* ៖ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) សេចក្ដីសម្រេចលើពាក្យសុំពិចារណាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ C22/I/68, កថាខណ្ឌ ២៥, (អ.ប.ជ៥៣), សាលដីកាសម្រេចអំពីការពិចារណាជាថ្មីឡើងវិញ អំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ D364/1/6។